# ឯកសារជំនួយស្មារតី
# ឯកឧត្តម គួច ចំរើន អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ
## ក្នុងសន្និសីទសារព័ត៌មាន ស្តីពីភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក
## របស់រដ្ឋបាលខេត្តព្រះសីហនុ

នៅទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣

**ជាបឋម ខ្ញុំព្រះករុណា-ខ្ញុំបាទ៖**

- សូមក្រាបថ្វាយបង្គំសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ !
- សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !
- សូមគោរព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- សូមគោរព ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ជាទីគោរព!
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មាន ដែលមានវត្តមាននៅក្នុងឱកាសនេះ ជាទីគោរពរាប់អាន!

ថ្ងៃនេះ តាងនាមរដ្ឋបាលខេត្តព្រះសីហនុ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវសេចក្តីសោមនស្សរីករាយ ដែលត្រូវបានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលអញ្ជើញឱ្យចូលរួមជាវាគ្មិនកិត្តិយស ដើម្បីធ្វើបទបង្ហាញអំពី **ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តព្រះសីហនុ** នាពេលនេះ។

អនុញ្ញាតឱ្យខ្ញុំព្រះករុណា-ខ្ញុំបាទ សូមគោរពរាយការណ៍ជូនសម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អំពីស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ សក្តានុពល និងសមិទ្ធផលនានាដែលរដ្ឋបាលខេត្តព្រះសីហនុសម្រេចបានក្នុងរយៈពេល ៥ឆ្នាំកន្លងមកដូចតទៅ៖

## I. ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ

ខេត្តព្រះសីហនុ ស្ថិតនៅប៉ែកនិរតីនៃប្រទេសកម្ពុជា ជាប់នឹងតំបន់ឆ្នេរសមុទ្រ មានចំងាយ ២៣០ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ៤ និងមានចំងាយ ២៦០គីឡូម៉ែត្រ តាមផ្លូវជាតិលេខ៣ មានអាកាសយានដ្ឋានអន្តរជាតិកងកេង កំពង់ផែអន្តរជាតិទឹកជ្រៅ និងមានផ្លូវល្បឿនលឿន (ភ្នំពេញ-ព្រះសីហនុ) មានចម្ងាយ ១៨៧,៥គីឡូម៉ែត្រ។ ខេត្តព្រះសីហនុ មានព្រំប្រទល់៖ ខាងជើងជាប់នឹងខេត្តកោះកុង ខាងត្បូង និងខាងលិចជាប់នឹងឈូងសមុទ្រថៃឡង់ដ៍ ខាងកើតជាប់នឹងខេត្តកំពត និងខេត្តកំពង់ស្ពឺ។

ចំពោះការគ្រប់គ្រងរដ្ឋបាលដែនដី ខេត្តចែកចេញជា ២ក្រុង ៣ស្រុក ២៣ឃុំ និង៦សង្កាត់ មានភូមិចំនួន១១១ភូមិ មានប្រជាពលរដ្ឋរស់នៅសរុបចំនួន ៥០.៥២២គ្រួសារ ស្មើនឹងមនុស្សសរុបចំនួន ២២៩.៣៣២នាក់មានដង់ស៊ីតេប្រជាជន ៨៦,២៥នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ (ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ ឆ្នាំ២០២១ របស់មន្ទីរផែនការ)។ផ្អែកតាមទិន្នន័យជំរឿន ឆ្នាំ២០១៩ ខេត្តមានប្រជាពលរដ្ឋប្រមាណ ៣១០.០០០នាក់ ។

ប្រជាពលរដ្ឋប្រកបមុខរបរកសិកម្មជាចម្បងមាន ២៣,៦០% សិប្បកម្ម ១,៨០% និងសេវាកម្ម ៧៤,៦០%។ អត្រាប្រាក់ចំណូលប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋម្នាក់ៗមានចំនួន ៤.១៨០ដុល្លារអាមេរិក និង មានអត្រាកំណើនសេដ្ឋកិច្ច ៦,៨% ដែលធ្វើឱ្យអត្រាភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងខេត្តថយចុះមកត្រឹម ១,៨៦% នៅឆ្នាំ២០២២។

ខេត្តមានផ្ទៃដីសរុប ២.៦៥៨,៩០គីឡូម៉ែត្រការ៉េ ស្ថានភាពផ្ទៃដី២/៣ ជាដីព្រៃភ្នំនិងខ្ពង់រាប ផ្ទៃដីគោក ២.៤៩៦,៥១គីឡូម៉ែត្រការ៉េ កោះចំនួន ៣២ (កោះចំនួន២ជាថ្មដុះ និងថ្មប៉ប្រះទឹក៥) មានផ្ទៃដី ១៦២,៣៩ គីឡូម៉ែត្រការ៉េ មានឆ្នេរសមុទ្រប្រវែង ១៧៥,៨១គីឡូម៉ែត្រ, និងមានព្រៃកោងកាង ១៣.៥០០ហិកតា ផ្កាថ្ម ១.១៩៨ហិកតា ព្រមទាំងស្មៅសមុទ្រ ២.៧១០ហិកតា។

ខេត្តព្រះសីហនុ ជាខេត្តដែលមានវិស័យសេដ្ឋកិច្ចសំខាន់ៗរួមមានៈ វិស័យឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ និងកសិកម្ម ដែលជាវិស័យអាទិភាពសម្រាប់ការអភិវឌ្ឍឿនសេដ្ឋកិច្ចជាតិរបស់រាជរដ្ឋាភិបាល ។ សក្តានុពលរួមមានៈ កំពង់ផែសមុទ្រទឹកជ្រៅ តំបន់សេដ្ឋកិច្ចពិសេស មានចំនួន១១ ទីតាំង (៣កំពុងដំណើរការ និង៨ត្រៀមដំណើការ) អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ និងឆ្នេរសមុទ្រដ៏ស្រស់ស្អាតដែលត្រូវបានប្រសិទ្ធនាមជា "**តារាវៈនាទិសនិរតី**" ។

**ការរៀបចំផែនការមេ ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង**

ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ នៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានពិភាក្សាអនុម័តលើសេចក្តីព្រាង "គោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីដើម្បីអភិវឌ្ឍខេត្តព្រះសីហនុនៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណងឆ្នាំ២០២២-២០៣៨"។ គោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង សំដៅដល់ការរៀបចំគោលនយោបាយគ្រប់គ្រងវិស័យដីធ្លីដែលក្នុងនោះមានៈ អនុវិស័យរដ្ឋបាលដីធ្លី អនុវិស័យរៀបចំដែនដីការគ្រប់គ្រង និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាក្នុងខេត្តព្រះសីហនុ អនុវិស័យបែងចែកដីធ្លី និងលំនៅឋាន ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យសំណង់ និងវិស័យពាក់ព័ន្ធដីធ្លី ផ្អែកលើមូលដ្ឋាននៃគោលនយោបាយដីធ្លី«សៀវភៅសដីធ្លី»។ សេចក្តីព្រាងគោលនយោបាយនេះមានចក្ខុវិស័យដល់ឆ្នាំ២០៣៨ «អភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ជាទីក្រុងបៃតងអាស៊ាននៃប៉ូលអភិវឌ្ឍជាតិទំនើបប្រកដោយចីរភាព សុខភាព និងសុភមង្គល តាមរយៈការជំរុញសមាហរណកម្មការអភិវឌ្ឍទីក្រុងឆ្លាត ការអភិវឌ្ឍបៃតង រមណីយដ្ឋានឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក មជ្ឈមណ្ឌលកំណើនជាតិ មជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិ ប្រកចេញចូលអន្តរជាតិ មជ្ឈមណ្ឌលភស្តុភារកម្មជាតិ ដោយមានទំនាក់ទំនងជាមួយទីផ្សារអាស៊ាន និងសកលលោក មជ្ឈមណ្ឌលឧស្សាហកម្មវិទ្យាសាស្ត្របច្ចេកវិទ្យាទំនើប និងនវានុវត្តន៍ ដែលមានសុខដុមនីយកម្មជាមួយនឹងបរិស្ថានរស់នៅល្អប្រសើរ និងរក្សាបាននូវអត្តសញ្ញាណ វប្បធម៌ និងប្រវត្តិសាស្ត្រជាតិ» និងមានគោលបំណងផ្តល់ក្របខ័ណ្ឌនិងតម្រង់ទិសការគ្រប់គ្រង ការប្រើប្រាស់ដីធ្លីការបែងចែកដីធ្លីការអភិវឌ្ឍដែនដី និងនគរូបយកម្មដើម្បីអភិវឌ្ឍខេត្តព្រះសីហនុ និងឧត្តមភាពវានុវត្តន៍ខ្ពស់សំដៅរួមចំណែកប្រែក្លាយកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

## II. សមិទ្ធផលសំខាន់ៗដែលសម្រេចបាន

### ១. ការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩

**ក. លទ្ធផលចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ក្នុងខេត្តៈ (គិតត្រឹមថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣)**

- សរុបការចាក់វ៉ាក់សាំងលើកទី១ ចំនួន ២៩៣.៩២៨នាក់ ស្រី ១៤៣.៣៦១នាក់
- សរុបការចាក់វ៉ាក់សាំងលើកទី២ ចំនួន ២៧៨.៦៥៨នាក់ ស្រី ១៣៦.៤២៩នាក់
- សរុបការចាក់វ៉ាក់សាំងលើកទី៣ ចំនួន ២៣០.៣៥៥នាក់ ស្រី ១១៣.៩៥៥នាក់
- សរុបការចាក់វ៉ាក់សាំងលើកទី៤ ចំនួន ៨៩.១៤៦នាក់ ស្រី ៤៤.៩៥៥នាក់
- សរុបការចាក់វ៉ាក់សាំងលើកទី៥ ចំនួន ៣៩.៦៩១នាក់ ស្រី ២០.៣៣៧នាក់
- សរុបការចាក់វ៉ាក់សាំងលើកទី៦ ចំនួន ១.៨៥៧នាក់ ស្រី ៣៨៤នាក់។

**ខ. ចំនួនករណីកូវីត ១៩ និង ការយកសំណាកសរុប**

- ករណីវិជ្ជមានជម្ងឺកូវីដ១៩សរុបចំនួន ១២.៨៧៥នាក់ ស្រី ៦.៧៣៦នាក់
- សរុបអ្នកជម្ងឺព្យាបាលជាសះស្បើយសរុបចំនួន ១២.៧១៨នាក់ ស្រី ៦.៦៥១នាក់
- សរុបការយកសំណាក ២៧៥.២៧១សំណាក។

**គ. ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ**

- រដ្ឋបាលខេត្តបានសាងសង់មន្ទីរពិសោធន៍កូវីដ ១៩ សម្រាប់ធ្វើតេស្តរកមេរោគកូវីដ១៩ និងការវិភាគអមវេជ្ជសាស្ត្រផ្សេងៗទៀត
- អគារព្យាបាលជំងឺកូវីដ ១៩ ដែលមានចំនួនគ្រែ ២២៩
- សាងសង់ និងបំពាក់ម៉ាស៊ីនផលិតអ៊ុកស៊ីសែនដែលមានសមត្ថភាពផលិតអ៊ុកស៊ីសែនបានចំនួន ៣០០០ លីត្រ ក្នុង០១ថ្ងៃ
- ជួសជុលអាគារសំរាប់ដាក់អ្នកជំងឺកូវីដ ១៩ ដែលជាទណ្ឌិត
- លើកកំពស់ផ្លូវមួយខ្សែក្នុងមន្ទីរពេទ្យខេត្ត (អ៊ុតកៅស៊ូ)

**ឃ. ការឧបត្ថម្ភសាច់ប្រាក់ជូនអ្នកស្លាប់ដោយសារកូវីដ ១៩**

អនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត បានបើកប្រាក់ ឧបត្ថម្ភជូនគ្រួសារអ្នកជំងឺស្លាប់ដោយសារកូវីដចំនួន ១៥៨សព ក្នុងនោះៈ

- សពទទួលបានការឧបត្ថម្ភចំនួន ៥ លានរៀលមានចំនួន ២៩ សព
- សពទទួលបានការឧបត្ថម្ភចំនួន ២ លានរៀលមានចំនួន ១២៩សព (ក្នុងនោះក៏មានបន្ថែមថវិកា សំរាប់ឈាបនកិច្ចចំនួន ១លានរៀល ក្នុងសពនីមួយៗ) សរុបជាទឹកប្រាក់ចំនួន ៥៣២.០០០.០០០៛
- ក្នុងព្រឹត្តការណ៍សហគមន៍ ២០កុម្ភៈ ២០២១ និងអ្នកជាប់ធ្វើចត្តាឡីស័កអំឡុងពេលបិទខ្ទប់ក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ រដ្ឋបាលខេត្តបានទទួលអំណោយ គ្រឿងឧបភោគបរិភោគដ៏ថ្លៃថ្លារបស់**សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** សរុបចំនួន ៣៦.០០០កញ្ចប់ សម្រាប់ចែកជូនប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩ ដោយរដ្ឋបាលខេត្តបាន ចែកជូនប្រជាពលរដ្ឋ ៣៤.៧២៣គ្រួសារ ស្មើនឹង៣៦.០០០កញ្ចប់។
- បានទទួលថវិកាដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាសរុបចំនួន ១.៥៦០.០០០.០០០រៀល និងឃីត (មុង ភួយ ខ្នើយ) ៣០០ឃីត សម្រាប់ចែកជូនកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ក្នុងអំឡុងពេលបិទខ្ទប់ និងគោលដៅធ្វើចត្តាឡីស័កក្នុងខេត្តព្រះសីហនុ។

- ដោយទទួលបានគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់ពី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា រដ្ឋបាលខេត្តបានខិតខំកៀរគរសប្បុរសជន ដើម្បីឧបត្ថម្ភសម្ភារ និងថវិកាសម្រាប់ សាងសង់អគារតេជោព្យាបាលជំងឺកូវីដ-១៩នៅក្នុងបរិវេណមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ សម្រាប់ព្យាបាលអ្នកជំងឺកូវីដ-១៩។ អគារនេះបានសម្ពោធប្រើប្រាស់ជាផ្លូវការ ដែលមានកម្ពស់ ១ជាន់ មានទំហំ ៣៣ម៉ែត្រx៩០ម៉ែត្រ ធ្វើពីគ្រឿងសសរបេតុង ដំបូលប្រក់ស័ង្កសី ដែលតម្លៃគម្រោងនេះ ចំណាយថវិកាអស់ចំនួន ១.៧៤២.៨៣០ដុល្លារអាមេរិក។

ក្នុងឱកាសដ៏មហាវិសេសវិសាលនេះ ខ្ញុំបាទសូមអនុញ្ញាតគោរពលើកឡើងអំពីវីរៈភាពរបស់ **សម្តេចតេជោ** នៅក្នុងបរិបទនៃការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នៅកម្ពុជា ជាពិសេសតាមរយៈការដោះស្រាយ និងចំណាត់ការលើព្រឹត្តិការណ៍ធំៗជាច្រើន បានបង្ហាញយ៉ាងច្បាស់ថា ប្រទេសតូចតាចមួយនេះក្រោមកណ្តាប់ដៃដែកថែប ទស្សនៈវិស័យត្រឹមត្រូវ ភាពម៉ឺងម៉ាត់ប្រកបដោយគតិបណ្ឌិត និងភាពឈ្លាសវៃ ព្រមទាំងការគោរពស្រលាញ់ និងការយកចិត្តទុកដាក់បំផុតលើសុខភាពប្រជាជនទូទៅ របស់ **សម្តេចតេជោ ហ៊ុន សែន** គឺពិតជាមានសមត្ថភាពពេញលេញក្នុងការគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩ ដ៏កាចសាហាវមួយនេះ បានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាពជាទីបំផុត ។ សម្តេចតេជោ មានបេះដូងមនុស្សធម៌ដ៏ពិតប្រាកដបង្កប់ដោយអត្ថន័យគោរពសិទ្ធិមនុស្ស ក្នុងការជួយដល់អ្នកទេសចរ និងនាវិកសរុបចំនួន ២.២៥៧នាក់ (ស្មើ៤១សញ្ជាតិ) ជាប់គាំងក្នុងនាវាខ្នាតយក្ស Westerdam របស់សហរដ្ឋអាមេរិក កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០(ខួប៣ឆ្នាំគិតឆ្នាំ២០២៣) និងការផ្តល់ជាជំនួយសម្ភារៈ និងបរិក្ខារពេទ្យ ជួយដល់ប្រទេសមួយចំនួន សម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩ នាពេលកន្លងមកនេះ បានបង្ហាញដល់សាធារណមតិ បណ្តាប្រទេសនានា និងពិភពលោកទាំងមូលថា កម្រមានប្រទេសណាដែល គ្រប់គ្រងស្ថានការណ៍បានរហ័ស លឿនទាន់ពេលវេលា និងកាត់ផ្តាច់បាននូវខ្សែចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសបានឆាប់និងល្អប្រសើរ ដូចមេដឹកនាំកម្ពុជាគឺ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នោះទេ។ ប្រទេសកម្ពុជាតូចតាចពិតមែន តែមានបេះដូងធំទូលាយ ដែលមនុស្សគ្រប់រូប និងគ្រប់ជាតិសាសន៍អាចជ្រកកោនរស់នៅក្រោមការដឹកនាំរបស់ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ក្នុងសុខសន្តិភាព និងការអភិវឌ្ឍ។ បច្ចុប្បន្នប្រជាពលរដ្ឋកម្ពុជាកំពុងរស់នៅក្នុងភាព សុខដុមរមនា ក្រោមដំបូល សន្តិភាព «**អរគុណសន្តិភាព**»។

## ២.ផ្នែកសង្គមកិច្ច

### ២.១.ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- គ្រួសារក្រីក្រទទួលបានប័ណ្ណសមធម៌ សរុប ៦.៧៦៣គ្រួសារ ក្នុងនោះគ្រួសារក្រីក្រកម្រិត១ មានចំនួន ២.៣៦៦គ្រួសារ និងគ្រួសារក្រីក្រកម្រិត២ មានចំនួន ៤.៣៩៧គ្រួសារ។
- គ្រួសារដែលងាយរងហានិភ័យ រស់ក្បែរបន្ទាត់ក្រីក្រ រងសម្ពាធពីបញ្ហាអតិផរណា និងដោយប្រការផ្សេងៗ មានចំនួនសរុប ៨.៦៦២គ្រួសារ។
- បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ កុមារអាយុក្រោម ២ឆ្នាំ នៅតាមក្រុង ស្រុក សរុបចំនួន ៤.៨៣៦នាក់ ក្នុងនោះស្ត្រីមានផ្ទៃពោះ ១.៤៨៨នាក់ ស្ត្រីនិងកុមារ ៣.៣៤៩នាក់ ដោយចំណាយថវិកាសរុប ១.៣៧៩.៤៨០.០០០រៀល។

- បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងជនងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ១៩ នៅតាមក្រុង-ស្រុក សរុបចំនួន ១៣.៦៦៦ប័ណ្ណ ដោយចំណាយថវិកាសរុបចំនួន ៤៣.១៦៩.៧១២.០០០រៀល។
- បានអនុវត្តកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារបិទខ្ទប់ ឆ្លង និងស្លាប់ដោយសារកូវីដ១៩ មានថវិកាសរុបចំនួន ២.៦៤៤.៤២៨.០០០រៀល។
- បានអនុវត្តកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសាររងហានិភ័យសម្ពាធអតិផរណា (លើកទី១) មានចំនួន ៦.៨៦៥គ្រួសារ ចំណាយថវិកា ១.០៥៩.៦៣០.៤០០រៀល និងអ្នកទទួលផលបានបើកប្រាក់ពី បញ្ជរវីងចំនួន ៦.៥៦៨គ្រួសារ ចំណាយថវិកា ១.០១៣.៩៦៤.៤០០រៀល។
- បានអនុវត្តកម្មវិធីជំនួយសង្គម (គាំពារសង្គមកម្ពុជា) ដោយឧបត្ថម្ភជាសាច់ប្រាក់ដល់កម្មករនិយោជិតវិស័យកាត់ដេរ និងទេសចរណ៍ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតី នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល ចំនួន ១១.១០៧នាក់ នៃ ៣៩សហគ្រាស ចំណាយថវិកា ២.៦៤៧.២៨៦.៨៥០រៀល។
- បានអនុវត្តការងារគាំពារដោយបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) ចំនួន ១.០៨៥គ្រួសារ ចំណាយថវិកា ២៦.៨១១.៥៦១.១៤០រៀល
- បានអនុវត្តការងារគាំពារដោយបេឡាជាតិសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន(ប.ជ.អ) ចំនួន ១.៣៥១ គ្រួសារ ចំណាយថវិកា ២១.៨១៩.៩០១.៥៩១រៀល។

## ៣.ការគ្រប់គ្រងរដ្ឋបាល

### ៣.១ ការផ្តល់សេវាសាធារណៈ

រយៈប្រាំឆ្នាំគិតចាប់ពី ខែកក្កដា ឆ្នាំ២០១៨ ដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២ អង្គភាពច្រកចេញចូលតែមួយ រដ្ឋបាលខេត្តព្រះសីហនុបានផ្តល់សេវា **សរុបចំនួន៖ ៥៤.៩៥៧**សេវា និងប្រមូលចំណូលសរុប៖ **២៧.៦២៨.៨៩៤.៨០០**រៀល ក្នុងនោះ **៨៦២.៥១៣.៩០០**រៀល ទូទាត់តាមប្រព័ន្ធអនឡាញ ទៅក្នុងគណនីអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណៈការ និងដឹកជញ្ជូន។

### ៣.២ ការងារហិរញ្ញវត្ថុ

ក្នុងរយៈពេល៥ឆ្នាំ រដ្ឋបាលខេត្តបានប្រមូលចំណូលសរុបចំនួន **៦៥៣.៦៨២.២៨២.៨៨៧រៀល** និងចំណាយសរុបចំនួន **៣៨៣.៣១៨.៦៩៣.៣៥០រៀល**។

### ៣.៤ ការងារគណៈកម្មាធិការលទ្ធកម្ម

ក្នុងរយៈពេល៥ឆ្នាំ គណៈកម្មាធិការលទ្ធកម្ម បានប្រគល់ ទទួលកិច្ចលទ្ធកម្មសរុបចំនួន ១៦១គម្រោង ក្នុងនោះ លទ្ធកម្មទំនិញ ៤០គម្រោង សំណង់ ១១៦គម្រោង និងសេវាកម្ម ៥គម្រោង។

## ៤.ការងារគម្រោងវិនិយោគខេត្ត

### ៤.១. ការងារអនុវត្តគម្រោង

ការអនុវត្តគម្រោងវិនិយោគខេត្តឆ្នាំ២០១៨-២០២២ ស្ថានភាពនៃការអនុវត្តគម្រោង មានចំនួនសរុប ១.១៨៦គម្រោង ជាលទ្ធផលបានបញ្ចប់ចំនួន ៥៩៥គម្រោង កំពុងដំណើរការ ២៩០គម្រោង មិនទាន់ដំណើរការ ៣០១គម្រោង មានទុនវិនិយោគសរុបចំនួន **១.០៦៤.៤៩៥,៣៧(លានរៀល)**។

ក្នុងឆ្នាំ២០២២ រដ្ឋបាលខេត្តព្រះសីហនុ បានកំពុងដំណើការសាងសង់ អគាររដ្ឋបាលសាលាខេត្តថ្មី មានកម្ពស់ ៥ជាន់ និងមានផ្ទៃក្រឡាសំណង់សរុប ៤៩.៣៨៤ម៉ែត្រក្រឡា។

### ៤.២.ការងារគាំទ្រមូលដ្ឋាន

**ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តខេត្ត រយៈពេល៥ឆ្នាំ**

រដ្ឋបាលខេត្ត បានជួសជុលផ្លូវចាក់បេតុងបានទំហំ ៤០៩.៥៧៥ម៉ែត្រការ៉េ ផ្លូវចាក់ក្រាល កៅស៊ូDBST បានចំនួន ២៦.៤៩៥ម៉ែត្រការ៉េ ផ្លូវចាក់ក្រាលកៅស៊ូAC បានចំនួន៦១.៩៣៧ម៉ែត្រការ៉េ ជួសជុលផ្លូវសំបុក មាន់បានចំនួន ៦.៥៧០ម៉ែត្រការ៉េ ជួសជុលស្ពានបានចំនួន៥ទីតាំង ជួសជុលសាលប្រជុំធំសាលាខេត្ត ព្រះសីហនុបានចំនួន១ទីតាំង ជួសជុលរង្វង់មូលត្រីដាវ បានចំនួន ១ទីតាំង ការងារគំនូសចរាចរណ៍បានចំនួន ៣ទីតាំង ជួសជុលកាំ ជណ្ដើផ្ទេរអូរឈើទាលបានចំនួន១ទីតាំង ជួសជុលសួនសាធារណៈបានចំនួន១៤ទីតាំង ជួសជុលភ្លើងបំភ្លឺសាធារណៈបានចំនួន១០ទីតាំង ជួសជុលភ្លើងស្តុបបានចំនួន៦ទីតាំង សាងសង់អគារ សាលាឃុំបានចំនួន ៣ទីតាំង ជួសជុលមត្តេយ្យសិក្សាសហគមន៍បានចំនួន៥ទីតាំង សាងសង់បង្គន់អនាម័យ បានចំនួន៥ទីតាំង ជួសជុលបណ្ដាញលូបានប្រវែង១៨.៨៣៩ម៉ែត្រ សាងសង់អគារច្រកចេញចូលតែមួយក្រុង កោះរ៉ុងបាន ចំនួន១ទីតាំង សាងសង់មណ្ឌលសុខភាពក្រុងកោះរ៉ុងបានចំនួន១ទីតាំង សាងសង់អគាររដ្ឋបាល ក្រុងកោះរ៉ុង បានចំនួន១ទីតាំង ជួសជុលក្លោងទ្វា និងរបងសាលាខេត្តបានចំនួន១ទីតាំង បង្ហោះជ្រូនសិក្សា ភូមិសាស្ត្រក្នុងខេត្តព្រះសីហនុបានចំនួន ១គម្រោង ជួសជុលលូប្រអប់បានចំនួន៦ទីតាំង ការងារដាំបង្គោល ស៊ីម៉ងត៍សុវត្ថិភាព បានប្រវែង២០០ម៉ែត្រ ជួសជុលអាគារច្រកចេញចូលតែមួយខេត្តចំនួន២៨០ម៉ែត្រការ៉េ ការងាររៀបជញ្ជាំង ប្រឡាយធ្វើពីបេតុង(Sheet Pile) បានប្រវែង៤៧៧ម៉ែត្រ ការងារស្តារប្រឡាយស្តារលូបាន ប្រវែង ៣៧.៥៧២ ម៉ែត្រ ការងាររៀបឧបករណ៍ស្ទាក់សម្រាមបានចំនួន ១ទីតាំង។

**ផ្លូវលំជនបទដែលប្រើប្រាស់ថវិកាមូលនិធិឃុំ-សង្កាត់ រយៈពេល៥ឆ្នាំ**

បានសាងសង់ផ្លូវចាក់បេតុងអាម៉េបានចំនួន ៧៧.៣៩៣ម៉ែត្រការ៉េ សាងសង់ផ្លូវលំគ្រួសធម្មជាតិបានចំនួន ១២.០៤៤ម៉ែត្រការ៉េ លូប្រអប់រំដោះទឹកបានចំនួន ១២ទីតាំង លូមូលរំដោះទឹកបានចំនួន ២ទីតាំង ទំនប់បង្វៀរ បានចំនួន ១ទីតាំង លូអ៊ុយរៀបថ្មភ្នំបានទំហំ ២៥៧ម៉ែត្រការ៉េ លូមូលកាត់ទទឹងផ្លូវបានចំនួន ៦ទីតាំង សាងសង់ ផៃបេតុងអាមេបានទំហំ ៥៨ម៉ែត្រការ៉េ។

### ៤.៣. ការងារវិនិយោគ

**ក.គម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់ធម្មជាតិខ្នាតតូច ( ទំហំក្រោម ១០ហិកតា)**

- រយៈពេល ៥ឆ្នាំកន្លងមក ក្រុមហ៊ុនវិនិយោគដែលទទួលបានគោលការណ៍ពីក្រសួងបរិស្ថាន វិនិយោគ អភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់ធម្មជាតិខ្នាតតូច( ទំហំក្រោម ១០ហិកតា) មានសរុបចំនួន **៥៨គម្រោង**។

**ខ.គម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍រយៈពេលវែង តាមបណ្ដាកោះ-ឆ្នេរ**

- ក្រុមហ៊ុនវិនិយោគដែលទទួលបានសិទ្ធវិនិយោគពីរាជរដ្ឋាភិបាល អភិវឌ្ឍន៍តាមបណ្ដាកោះ និងឆ្នេរ សរុបចំនួន ២៧ក្រុមហ៊ុន មានទុនវិនិយោគសរុប **៨.៩០០.៥៧០.២៥១ដុល្លារ**។

**គ. អនុគណៈកម្មាធិការវិនិយោគខេត្តព្រះសីហនុ**

- គម្រោងវិនិយោគដែលទទួលបានគោលការណ៍ពីអនុគណៈកម្មាធិការវិនិយោគខេត្តចំនួន ០១ គម្រោង វិនិយោគលើវិស័យឧស្សាហកម្ម (កែច្នៃម្ហូបអាហារ) **មានទុនវិនិយោគ ១.៧៥៣.៩០០ (ដុល្លារ)**

**ឃ.គម្រោងវិនិយោគដែលទទួលបានគោលការណ៍ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

- ក្រុមហ៊ុនវិនិយោគ ដែលទទួលបានសិទ្ធិវិនិយោគពីរាជរដ្ឋាភិបាលអភិវឌ្ឍន៍ គិតពីឆ្នាំ ១៩៩៤-២០២២ មានចំនួន ២០០ក្រុមហ៊ុន មានទុនវិនិយោគសរុប **៣០.១៩៤.១៥៩.៧៦៦ដុល្លារ**
- តំបន់សេដ្ឋកិច្ចពិសេសមានចំនួន ១១តំបន់ មានទុនវិនិយោគសរុប **១.៤៨១.៣៥៨.៨០២ដុល្លារ**។

នៅក្នុងឆ្នាំ២០២២ មានគម្រោងស្នើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេសចំនួន ០២ផងដែរ(មានទីតាំងនៅស្រុកព្រៃនប់ និងស្រុកកំពង់សីលា) ដែលមានការគាំទ្រពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ប៉ុន្តែនៅរង់ចាំការសម្រេចពីរាជរដ្ឋាភិបាល។

## ៥. ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធប្រើប្រាស់កញ្ចប់ថវិកាសន្សំរបស់រាជរដ្ឋាភិបាល និងការវិនិយោគរបស់វិស័យឯកជន

### ៥.១ ថវិកាស្ដីកន្លោតខូបស្ដុរន្លោត

គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន ៣៧ខ្សែ ប្រវែងសរុប ៨៤.០៦៥ម៉ែត្រ ចំណាយអស់ទឹកប្រាក់សរុប ៣២៤.០៧៩.៩៦៤ដុល្លារ ក្នុងនោះថវិការបស់រាជរដ្ឋាភិបាលចំនួន ៣១០.៤៦៦.២៧៦ដុល្លារ ក្រុមហ៊ុនVINCI ចំនួន១០.១៦៣.៥៩៣ដុល្លារ និងឯកឧត្តមអ្នកឧកញ៉ា លី យ៉ុងផាត់ ៣.០០០.០០០ដុល្លារ។ រចនា សម្ព័ន្ធផ្លូវក្រុងចំនួន ៣៧ខ្សែ រួមមាន មហាវិថីចំនួន ៣ខ្សែ ប្រវែង ២០.៨៦៤ម៉ែត្រ វិថីចំនួន ១៥ខ្សែ ប្រវែង ៥០.៣៣៤ម៉ែត្រ និងអនុវិថីចំនួន ១៩ខ្សែ ប្រវែង ១២.៨៦៧ម៉ែត្រ និងហេដ្ឋារចនាសម្ព័ន្ធមួយចំនួនទៀតដូចខាងក្រោម៖

- **ចិញ្ចើមផ្លូវ៖** បានរៀបចំខឿនថ្មក្រានីតប្រវែង ២១៣.៤០៨ម៉ែត្រ និងកម្រាលថ្មក្រានីតចំនួន ៥៣៩.៦៨៦ ម៉ែត្រការ៉េ ដោយមានការរៀបចំផ្លូវថ្មើរជើង ផ្លូវកង់ ផ្លូវសម្រាប់ជនមានពិការភាពជាដើម។
- **ដើមឈើ ដើមផ្កា និងស្មៅ៖** បានដាំដើមឈើចំនួន ៨ប្រភេទ លម្អតាមដងផ្លូវទាំង ៣៧ខ្សែ សរុបចំនួន ១២.៦១៨ដើម ផ្កាក្រដាស ៦០.២០០គុម្ព នៅតាមមេដ្យាននៃមហាវិថីទាំង៣ និងដាំស្មៅ ២៩៦.៧៧១ម៉ែត្រការ៉េ។
- **បង្គោលភ្លើងបំភ្លឺផ្លូវ និងអំពូលឆ្លាតវៃ៖** បានដំឡើងបង្គោលភ្លើងបំភ្លឺផ្លូវចំនួន ៤.៦២៨បង្គោល និងបំពាក់អំពូល ឆ្លាតវៃចំនួន ៥.៣០០អំពូល។
- **សញ្ញាចរាចរណ៍៖** បានតំឡើងភ្លើងសញ្ញា (ភ្លើងស្តុប) ចំនួន ៣៤ទីតាំង បំពាក់ស្លាកសញ្ញា ១.១៧៧ ស្លាក គំនូសសញ្ញាចរាចរណ៍ចំនួន ៩០.៦៤០ម៉ែត្រការ៉េ និងដាក់ភ្នែកឆ្មា(Road Stud) ចំនួន ៩.១៥៥គ្រាប់
- **ប្រព័ន្ធបណ្តាញលូ៖** បានសាងសង់លូប្រអប់កាត់ទទឹងថ្នល់ចំនួន ៤១ទីតាំង ប្រវែង ១.៥៤៣ម៉ែត្រ លូមូលកាត់ទទឹងថ្នល់ចំនួន ៧៦ទីតាំង ប្រវែង ២.០៣១ម៉ែត្រ លូទឹកភ្លៀងអង្កត់ផ្ចិត ១ម៉ែត្រប្រវែង ៨៨.៨៩៧ម៉ែត្រ លូទឹកកខ្វក់អង្កត់ផ្ចិត១ម៉ែត្រ ប្រវែង ៨១.៦៥៣ម៉ែត្រ ប្រឡាយរាងអក្សរអ៊ុយ ប្រវែង ៧.៤០៦ម៉ែត្រ និង ប្រឡាយអក្សរវី ប្រវែង ៦ ៧៨៤ម៉ែត្រ
- **ស្ថានីយ៍ប្រព្រឹត្តិកម្មទឹកកខ្វក់៖** បានសាងសង់ស្ថានីយ៍ប្រព្រឹត្តិកម្មទឹកកខ្វក់ចំនួន ៣កន្លែង ក្នុងនោះ ស្ថានីយ៍ទី១ និងទី២បានដាក់ឱ្យដំណើរការជាស្ថាពរ ដែលស្ថានីយ៍ទី១ មានសមត្ថភាពប្រព្រឹត្តិកម្ម ៥.២០០ម$^{៣}$/ថ្ងៃ ស្ថានីយ៍ទី២ មានសមត្ថភាពប្រព្រឹត្តិកម្ម ៧.២០០ម$^{៣}$/ថ្ងៃ និងស្ថានីយ៍ទី៣ កំពុងដំណើរការសាងសង់បានប្រមាណ៨០ភាគរយ មានសមត្ថភាពប្រព្រឹត្តិកម្ម ២០.០០០ម$^{៣}$/ថ្ងៃ

- **សំណង់ស្ពាន៖** បានសាងសង់ស្ពានសរុបចំនួន ៩ទីតាំង ប្រវែងសរុប ២៩៦ម៉ែត្រ ក្នុងនោះមានស្ពាន ៦ទីតាំង មានទទឹង ២៥,៧៥ម៉ែត្រ ប្រវែង ២០២ម៉ែត្រ និងស្ពានចំនួន ៣ទីតាំង ទទឹងពី ១១,៥៦ ម៉ែត្រ ដល់ ២០,៥០ម៉ែត្រ មានប្រវែង ៩៤ម៉ែត្រ
- **រង្វង់មូល និងត្រីកោណប្រសព្វ៖** បានរៀបចំរង្វង់មូលចំនួន ៤ទីតាំង រួមមាន រង្វង់មូលកងកេង(នាគព័ន្ធ) រង្វង់មូលព្រះឧមា-មហេសូរ រង្វង់មូលព្រះថោងនាងនាគ និងរង្វង់មូលព្រះសីហរាជមុខបី និងត្រីកោណ ប្រសព្វចំនួន២ទីតាំងមានត្រីកោណប្រសព្វមហាវិថីជំទាវម៉ៅ និងត្រីកោណប្រសព្វព្រះស្តន្តទ្រង់ក្ងោក ដែលទីតាំងនីមួយៗមានលម្អ ដោយបដិមាធ្វើពីស្ពាន់ កម្រាលថ្មក្រានីត និងកម្រាលស្មួនស្មៅ ជាដើម
- **ចំណតរថយន្ត៖** បានរៀបចំចំណតរថយន្ត ដែលមានចំនួនសរុប ៧២៤ចំណត នៅតាមទីតាំងសំខាន់ៗ ជាពិសេសតំបន់ដែលមានសក្តានុពលផ្នែកទេសចរណ៍
- **បន្ទប់ទឹកសាធារណៈប្រណិត៖** បានសាងសង់បន្ទប់ទឹកសាធារណៈប្រកបដោយភាពប្រណិតចំនួន ៩ទីតាំង នៅតាមដងវិថីតេជោបណ្តោយឆ្នេរអូរឈើទាល ឆ្នេរអូរត្រេះ និងឆ្នេរពយជំទាវម៉ៅសម្រាប់បម្រើដល់សាធារណជន ភ្ញៀវទេសចរជាតិ និងអន្តរជាតិ
- **សួន ទីលាន និងទីសាធារណៈសំខាន់ៗ៖** បានរៀបចំស្ថាបនាសួន និងទីធ្លាសាធារណៈដែលមានដូចជា សាងសង់ទីលានតេជោទំហំ ២៣.៥៩៣ម៉ែត្រការ៉េ ទីអង្គុយកម្សាន្តពយអូរឈើទាល សួនសាធារណៈ ពយអូរឈើទាល ខ្មែរធ្វើបាន សិលាចាំស្នេហ៍ ដើមឈើចាំស្នេហ៍ ថ្មបីដុំ សួនឆ្នេរពយជំទាវម៉ៅ សួនកូនសោរ និងសួនរង្វង់មូលកងកេងជាដើម
- **ការស្តារអូរ ប្រឡាយ និងប្រព័ន្ធរំដោះទឹក៖** បានស្តារអូរ-ប្រឡាយធម្មជាតិចំនួន ៦ខ្សែ ប្រវែងសរុប ២៧.១១៧ ម៉ែត្រ ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធរំដោះទឹកភ្លៀងក្នុងក្រុងព្រះសីហនុ
- **ការពង្រីក កែលម្អ និងតភ្ជាប់ឆ្នេរ៖** បានពង្រីក និងកែលម្អឆ្នេរសមុទ្រ ការកែលម្អចិញ្ចើមផ្លូវ ការកែលម្អដីចំណីឆ្នេរសមុទ្រ និងការចាក់បំពេញខ្សាច់សជាដើម។ ការកែលម្អឆ្នេរចាប់ពីឆ្នេរសុខាដល់ឆ្នេររាម ប្រវែងសរុប១៨,៨៨គីឡូម៉ែត្រ បានរៀបចំផ្លូវថ្មើរជើងតាមបណ្តោយឆ្នេរប្រវែង ៩,៣២គីឡូម៉ែត្រ ពីវិថីតេជោ ដល់វិថីឆ្នេរពយជំទាវម៉ៅ ព្រមទាំងបានរៀបចំកែលម្អទីតាំងទេសចរណ៍សំខាន់ៗជាច្រើនទៀត។ ត្រូវបានភ្ជាប់ឆ្នេរសុខា និងឆ្នេរអូរឈើទាលតាមរយៈការស្ថាបនាវិថីតេជោ តភ្ជាប់ឆ្នេរអូរឈើទាល និងឆ្នេរអូរត្រេះ តាមរយៈការស្ថាបនាវិថីពយអូរឈើទាលតភ្ជាប់ឆ្នេរអូត្រេះ និងឆ្នេរពយជំទាវម៉ៅ តាមរយៈការស្ថាបនាស្ពានសែនត្រជាក់ចិត្ត និងការតភ្ជាប់ឆ្នេរពយជំទាវម៉ៅ នឹងឆ្នេររាម តាមរយៈការស្ថាបនាមហាវិថីជំទាវម៉ៅ នឹងមហាវិថីរាម
- **ការរៀបចំខ្ទស និងខ្លោងទ្វារឆ្នេរតាមមាត់សមុទ្រ៖** បានរៀបចំខ្ទសចំនួន ៤៤ នៅឆ្នេរអូរឈើទាល និង ៨ នៅឆ្នេរឯករាជ្យសម្រាប់សាធារណជន ភ្ញៀវទេសចរ និងខ្លោងទ្វារឆ្នេរចំនួន ១១ទីតាំង
- **ការរៀបចំស្ថានីយបូមទឹកកខ្វក់៖** បានរៀបចំស្ថានីយបូមទឹកកខ្វក់ចំនួន ៤ទីតាំង មានទីតាំងស្ថានីយទី១ នៅឆ្នេរឯករាជ្យ ទី២ នៅឆ្នេរសុខា ទី៣ នៅអូរសំអាត និងទី៤ នៅឆ្នេរអូរឈើទាល
- **ការស្ថាបនាវិថីតេជោ៖** បានស្ថាបនាវិថីតេជោ ដែលជាវិថីដ៏មានសារៈសំខាន់ និងជាវិថីបើកថ្មីភ្ជាប់ពីផ្លូវលេខ ៥០២ ទៅវិថី២ធ្នូ ដោយក្នុងនោះការងារចាក់បំពេញតួផ្លូវចូលសមុទ្រប្រវែង ១.០៣៤ម៉ែត្រ ដែលមានជម្រៅជាមធ្យមពី ៤ទៅ៦ម៉ែត្រ បានប្រើប្រាស់មាឧថ្មប្រមាណជា ៣៦៤.៤៩៦ម៉ែត្រគូប។ វិថីតេជោ ក៏បានស្ថាបនា ជាពិសេស ដែលមានចំណតរថយន្តសាធារណៈ ដែលអាចចតរថយន្តធុនធំ

ទេសចរណ៍ ១០ចំណត និងរថយន្ត ធុនតូច ១១៤ចំណត។ មិនត្រឹមតែប៉ុណ្ណោះថែមទាំងមានការស្ថាបនារូបបដិមាព្រះស្តន្តធ្វើពីស្ពាន់មានកម្ពស់ ៦,១៨ម៉ែត្រ និងមានកម្ពស់សរុបរួមទាំងខឿនបដិមា ១២,៣៦ម៉ែត្រ និងបានស្ថាបនាទីលានតេដោទំហំ ២៣.៥៩៣ម៉ែត្រការ៉េ ជាទីលានសាធារណៈ សម្រាប់លម្ហែកម្សាន្ត និងប្រារព្ធពិធីផ្សេងៗតាមតម្រូវការ។

## ៥.២. កញ្ចប់ថវិកាសន្សំរបស់រាជរដ្ឋាភិបាល ១២០ លានដុល្លា

- **គម្រោងធ្វើឱ្យប្រសើរឡើងផ្លូវខេត្តលេខ ១៤៦បេ (វិថីសម្តេចសង្ឃរាជទេពវង្ស) និងផ្លូវខេត្តលេខ ១៤៨ សរុបប្រវែង ៤៣.០២៥ម៉ែត្រ ៖** ដោយចាក់ក្រាលកៅស៊ូ AC ទទឹងសរុប ១១ម៉ែត្រ កម្រាស់៩សង់ទីម៉ែត្រ ប្រវែង ២០.៦៧៨ម៉ែត្រ, ចាក់បេតុងសរសៃដែកទទឹង ១១ម៉ែត្រ កម្រាស់២៦សង់ទីម៉ែត្រ ប្រវែង ២២.៣៤៧ម៉ែត្រ និងជួសជុលស្ពាន ១៧ទីតាំង បានសាងសង់ថ្មី ១ទីតាំង។
- **ជួសជុលពង្រីកកំណាត់ផ្លូវជាតិលេខ៤ ប្រវែង ៦.៧០០ម៉ែត្រ ទទឹង ២៩ម៉ែត្រ ៖** ដោយចាក់បេតុងសរសៃដែកកម្រាស់ ២៥សង់ទីម៉ែត្រ រួចចាក់ក្រាលកៅស៊ូ AC កម្រាស់ ១០សង់ទីម៉ែត្រ និងសំណង់សិល្បការ្យផ្សេងៗរួមមានៈ សួនបែងចែកទ្រូង, បង្គោលភ្លើងបំភ្លឺសាធារណៈ, ស្លាកសញ្ញាចរាចរ, គំនូសសញ្ញាចរាចរ, លូទឹកភ្លៀង, ផ្លូវថ្មើរជើងក្រោមដី ០២កន្លែង និងកន្លែងសម្រាប់បត់ត្រឡប់ក្រោយសម្រាប់រថយន្តគ្រប់ប្រភេទ ០២កន្លែង។
- **ជួសជុលផ្លូវក្នុងក្រុងចំនួន ១០ខ្សែ** ៖ (ផ្លូវលេខ ៨២៧, ៨២៣, ៨១៤, ១០៣, ១១០, ១៤៣, ១០៨៣, ២០៩, ២០០, ១០៤) សរុបប្រវែង ៩.៦៧៤ម៉ែត្រ ទទឹងចន្លោះពី៦ម៉ែត្រ ដល់២២ម៉ែត្រ ដោយចាក់បេតុងសរសៃដែកកម្រាស់ ២៥សង់ទីម៉ែត្រ រួចចាក់ក្រាលកៅស៊ូAC កម្រាស់ ៧សង់ទីម៉ែត្រ និង១០សង់ទីម៉ែត្រ និងសំណង់សិល្បការ្យផ្សេងៗរួមមានៈ បង្គោលភ្លើងបំភ្លឺសាធារណៈ, ស្លាកសញ្ញាចរាចរ, គំនូសសញ្ញាចរាចរ, ផ្លូវថ្មើរជើង, លូទឹកភ្លៀង, លូទឹកកខ្វក់ និងលូបណ្តាញផ្សេងៗ។
- **ការស្តារអូរ ប្រឡាយ និងប្រព័ន្ធរំដោះទឹក៖** បានស្តារអូរ-ប្រឡាយធម្មជាតិចំនួន ១០ខ្សែ ប្រវែងសរុប ២៧.១១៧ ម៉ែត្រ ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធរំដោះទឹកភ្លៀងក្នុងក្រុងព្រះសីហនុ

## ៥.៣. ថវិការាជរដ្ឋាភិបាលតាមរយៈក្រសួងសាធារណការ និងដឹកជញ្ជូន

### ៥.៣.១. អនុវត្តការងារដោយក្រសួងសាធារណការ និងដឹកជញ្ជូន

- **លើកកម្ពស់សមត្ថភាពស្ថានីយចម្រោះទឹកកខ្វក់អូរឈើទាល៖** ពី ៦.៩០០ម$^{៣}$/ថ្ងៃ ទៅ ៣០.០០០ម$^{៣}$/ថ្ងៃ
- **សាងសង់ស្ថានីយបូមទឹកកខ្វក់ចំនួន ០៤កន្លែង៖** (ស្ថានីយបូមទី២ មុខសាលាខេត្ត, ស្ថានីយបូមទី៣ បុរីអេម៉ារីយ៉ូ, ស្ថានីយបូមទី៦ ចុងអូរត្រេះ ផ្លូវលេខ៨៣៧ និងស្ថានីយបូម ៥០២ ផ្លូវលេខ៥០២ជាប់សមុទ្រ)
- **សាងសង់ទីលានទុកដាក់សំរាមសំណង់រឹង៖** ស្ថិតក្នុងឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

### ៥.៣.២. អនុវត្តការងារដោយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ

- **គម្រោងដោះស្រាយការជន់លិចក្នុងព្រះសីហនុ៖** ដោយសាងសង់លូប្រអប់មុខមួយ កម្ពស់២ម៉ែត្រ ទទឹង ៤ម៉ែត្រ ប្រវែង ៤០០ម៉ែត្រ និងលូប្រអប់មុខមួយ កម្ពស់ ២,៥០ម៉ែត្រ ទទឹង ៣ម៉ែត្រ ប្រវែង ១.០៣៥ម៉ែត្រ ចាប់ផ្លូវលេខ ៨១៨៨ ដល់សមុទ្រ។
- **ជួសជុលកំណាត់ផ្លូវជាតិលេខ ៤៥៖** ដោយចាក់ក្រាលកៅស៊ូ DBST ប្រវែង ៣.០០០ម៉ែត្រ ទទឹង ៨ម៉ែត្រ និងចាក់ក្រាលកៅស៊ូ AC កម្រាស់ ៨សង់ទីម៉ែត្រ ប្រវែង ១.៣៥០ម៉ែត្រ ទទឹង ៧ម៉ែត្រ

- **ជួសជុលកំណាត់ផ្លូវខេត្តលេខ ១៤៨៖** ដោយចាក់ក្រាលកៅស៊ូ DBST ប្រវែង ២.៨១០ម៉ែត្រ ទទឹង ៨ម៉ែត្រ និងចាក់ក្រាលបេតុងសរសៃដែក ប្រវែង ១៩០ម៉ែត្រ ទទឹង ៨ម៉ែត្រ កម្រាស់ ២០សង់ទីម៉ែត្រ
- **ស្ថាបនារង្វង់មូលសីហារាជមុខបី៖** និងបើកស្ពានបែងចែកទ្រូងផ្លូវជាតិលេខ ៤ ចំនួន ២កន្លែង។
- **ជួសជុលផ្លូវជាតិលេខ ៤៖** ដោយចាក់ក្រាលកៅស៊ូ AC ទំហំ៩៤.៧៤២ម៉ែត្រការ៉េ កម្រាស់ ៥សង់ទីម៉ែត្រ និងចាក់ក្រាលកៅស៊ូ DBST ទំហំ ៤១.០៨៥ ម៉ែត្រការ៉េ។
- **ថែទាំប្រចាំ៖** កំណាត់ផ្លូវជាតិលេខ ៤ ប្រវែង ៤៨គីឡូម៉ែត្រ

## ៦.ផ្នែកសេដ្ឋកិច្ច

### ៦.១.ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

#### ក. ការជំរុញផលិតកម្មដំណាំកសិកម្ម និងកសិធុរកិច្ចរយៈពេល៥ឆ្នាំ ២០១៨-២០២២

ការលើកកម្ពស់ខ្សែច្រវាក់តម្លៃដំណាំកសិកម្មរួមមាន៖ ផលិតកម្មដំណាំស្រូវ ចំនួនសរុប ១៨៣.៩៤១តោន ផលិតកម្មដំណាំសារប្បកម្មសរុបបាន ១២៧.៩៤៨តោន ផលិតកម្មដំណាំឧស្សាហកម្មសរុបបាន ១.២៤៤.៩៩៥តោន ផលិតកម្មដំណាំកៅស៊ូសរុបបាន ១១.៤១២តោន។

#### ខ. ការចិញ្ចឹមសត្វ លើកកម្ពស់សុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល

ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មកើនឡើងចំនួនសរុប ១.៤០២.៧៥៧ក្បាល សត្តឃាតដ្ឋានដែលបានអនុវត្តតាមបទដ្ឋានបច្ចេកទេសចំនួនសរុប ១០សត្តឃាត។

#### គ. ការការពារធនធានជលផល និងការអភិវឌ្ឍខ្សែច្រវាក់តម្លៃផលជលផល

សហគមន៍នេសាទត្រូវបានពង្រឹង និងគ្រប់គ្រងចំនួនសរុប ៧៥សហគមន៍ បរិមាណផលវារីវប្បកម្មចំនួនសរុប ៦.១៨៧តោន បរិមាណផលកែច្នៃផលជលផលចំនួនសរុប ៨.៩៣០តោន។

#### ឃ. ការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ

កូនឈើដែលបានដាំមានចំនួនសរុប ៥៦ ៦១៨ដើម បទល្មើសព្រៃឈើ និងសត្វព្រៃមាន ៩៤៨ករណី សហគមន៍បានអនុវត្តការងារកសិ-រុក្ខកម្មមានចំនួនសរុប ១០សហគមន៍។

#### ង. ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

លទ្ធផលនៃការអនុវត្តផែនការសកម្មភាព និងថវិកាបានអនុវត្តជាមធ្យមមាន ៩៦,៦៦% ក្នុងនោះអ្នកពាក់ព័ន្ធ ក្នុងផ្នែកកសិកម្មទទួលបានចំណេះដឹងបច្ចេកទេសកសិកម្មសរុប ៥.៩៣០នាក់ និងសេវាប្រើប្រាស់ព័ត៌មាន ទីផ្សារកសិផលចំនួនសរុប ៣៩៥នាក់។

### ៦.២. ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

#### ក. វិស័យឧស្សាហកម្មធុនធំ៖

ខេត្តព្រះសីហនុ មានតំបន់សេដ្ឋកិច្ចពិសេសសរុបចំនួន ១១តំបន់ ក្នុងនោះមាន ៣តំបន់ ដែលមានរោងចក្រកំពុងដំណើរការ និងរោងចក្រសរុបចំនួន **២៣៩រោងចក្រ** ក្នុងនោះ៖ រោងចក្រក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួនសរុប ១៦៨រោងចក្រ និងក្រៅតំបន់សេដ្ឋកិច្ចពិសេសមានចំនួនសរុប ៧១រោងចក្រ មានកម្លាំងពលកម្មសរុបចំនួន ៣៤.៤៧៩នាក់ មានទុនវិនិយោគសរុបចំនួន ២.២១១.៦៧១.000ដុល្លាអាមេរិក។

**ខ. វិស័យឧស្សាហកម្មធុនតូច (សហគ្រាស ធុនតូច និងមធ្យម និងសិប្បកម្ម)៖**

សហគ្រាស និងសិប្បកម្ម សរុបចំនួន **១.២១៣ មូលដ្ឋាន** ក្នុងនោះ៖ មានកម្លាំងពលកម្ម ៦.២៣១ នាក់ មានទុនវិនិយោគ ២៦ ៦៩៩ ៦១៩ ដុល្លាអាមេរិក។

**គ. ការងារចុះបញ្ជីច្រកចេញ-ចូលតែមួយនៅមន្ទីរ រដ្ឋបាលខេត្ត និងក្រុងស្រុក សរុបចំនួន ៧០១ សេវា** មានដូចខាងក្រោម៖

- **ការងារចុះបញ្ជីនៅច្រកចេញ-ចូលតែមួយរបស់មន្ទីរ៖** ចេញសេចក្ដីសម្រេចបង្កើត សហគ្រាស/សិប្បកម្ម និងវិញ្ញាបនបត្រអនុញ្ញាតដំណើរថ្មី និងបន្ត **សរុបចំនួន ៤០៨ សេវា**។
- **ការងារចុះបញ្ជី នៅច្រកចេញ-ចូលតែមួយ រដ្ឋបាលខេត្ត៖** ចុះបញ្ជីសិប្បកម្ម/ស្ថានីយ៍ប្រេងឥន្ធនៈ និងវិញ្ញាបនបត្រអនុញ្ញាតដំណើរថ្មី និងបន្ត **សរុបចំនួន ២០១ សេវា**។
- **ការងារចុះបញ្ជី នៅច្រកចេញ-ចូលតែមួយ រដ្ឋបាលក្រុងស្រុក៖** ចុះបញ្ជីសិប្បកម្ម និងវិញ្ញាបនបត្រអនុញ្ញាតដំណើរថ្មី និងបន្ត **សរុបចំនួន ៩២ សេវា**។

**+ ការងារផ្គត់ផ្គង់ទឹកស្អាត**

ក្រុមហ៊ុនទឹកស្អាត ក្នុងខេត្តព្រះសីហនុ សរុបចំនួន **១១ក្រុមហ៊ុន** ដែលកំពុងដំណើរការផ្គត់ផ្គង់ទឹកស្អាតតាមទីប្រជុំជនក្នុងខេត្ត បើប្រៀបធៀបចំនួនគ្រួសារ នៃតំបន់សេវាកម្ម រយៈពេល០៥ ឆ្នាំកន្លងមក យើងទទួលបានលទ្ធផលដូចតទៅ៖ ក្រុងព្រះសីហនុ ផ្គត់ផ្គង់បាន១០៨% ក្រុងកោះរ៉ុង ផ្គត់ផ្គង់បាន ២៦% ស្រុកព្រៃនប់ ផ្គត់ផ្គង់បាន ៣០% ស្រុកស្ទឹងហាវផ្គត់ផ្គង់បាន ៧៩% និងស្រុកកំពង់សីលា ផ្គត់ផ្គង់បាន ០១%

**សរុបជារួម** សម្រាប់ខេត្តព្រះសីហនុទាំងមូល ការផ្គត់ផ្គង់ទឹកស្អាតតាមទីប្រជុំជន មានចំនួន **៦៤%។**

## ៦.៣. ថាមពលអគ្គិសនីខេត្ត

- អគ្គិសនីខេត្តព្រះសីហនុ មានប្រភពផ្គត់ផ្គង់សំខាន់ៗចំនួន ១២ ដែលកំពុងដំណើរការដូចជា៖ អង្គភាពអគ្គិសនីខេត្តព្រះសីហនុផ្គត់ផ្គង់ថាមពលដំណើរការដោយម៉ាស៊ីនWartsila ០៤មេហ្គាវ៉ាត់ អនុស្ថានីយស្ទឹងហាវផ្គត់ផ្គង់ថាមពលបាន ៥០មេហ្គាវ៉ាត់ អនុស្ថានីយក្រុងព្រះសីហនុ ផ្គត់ផ្គង់ថាមពលបាន ១៥០ មេហ្គាវ៉ាត់ អនុស្ថានីយតាតៃ ផ្គត់ផ្គង់ថាមពលបាន ៦០មេហ្គាវ៉ាត់ រោងចក្រSchneitec ផ្គត់ផ្គង់ ថាមពលបាន ២៣មេហ្គាវ៉ាត់ ប្រភពពីខេត្តកំពតផ្គត់ផ្គង់ថាមពលបាន ០៧មេហ្គាវ៉ាត់ អនុស្ថានីយចំការហ្លួង ផ្គត់ផ្គង់ថាមពលបាន ៤០មេហ្គាវ៉ាត់ អនុស្ថានីយបុទមសាគរ ផ្គត់ផ្គង់ថាមពលបាន ៥០មេហ្គាវ៉ាត់ អនុស្ថានីយរាមផ្គត់ផ្គង់ថាមពលបាន ៥០មេហ្គាវ៉ាត់ អនុស្ថានីយខេមរភូមិន្ទផ្គត់ផ្គង់ថាមពលបាន ៥០ មេហ្គាវ៉ាត់ អនុស្ថានីយអូរគ្រេះផ្គត់ផ្គង់ថាមពលបាន ១៥០មេហ្គាវ៉ាត់ និង អនុស្ថានីយឆ្នេរសុខាផ្គត់ផ្គង់ថាមពលបាន ១៥០មេហ្គាវ៉ាត់។

  សរុបប្រភពផ្គត់ផ្គង់ថាមពលអគ្គិសនីខាងលើនេះបានចំនួន ៧៨៤ មេហ្គាវ៉ាត់
- រោងចក្រផលិតអគ្គិសនី ប្រើឡចំហាយដើរដោយធ្យូងថ្មក្នុងស្រុកស្ទឹងហាវមាន ចំនួន០៣ ក្រុមហ៊ុន សម្រាប់ផលិតអគ្គិសនីបញ្ជូនតាមរយៈខ្សែបណ្ដាញបញ្ជូនជាតិ រួមមាន៖ ក្រុមហ៊ុន Cambodia Energy Limited (CEL) អាចផលិតអនុភាព ២៣៥ មេហ្គាវ៉ាត់ ក្រុមហ៊ុន Cambodia International

Investment Group (CIIDG) អាចផលិតអនុភាព ៣៦០មេហ្គាវ៉ាត់ ក្រុមហ៊ុន Huadian Sihanouk Power Generation (HSPG) អាចផលិតអនុភាព ៧០០មេហ្គាវ៉ាត់។

- អគ្គិសនីខេត្តព្រះសីហនុមានខ្សែបណ្តាញ គ្របដណ្តប់ខេត្តព្រះសីហនុ លាត់សន្ធឹងដល់ត្រពាំងរពៅ ព្រំប្រទល់ខេត្តកំពត ដល់ត្រែងត្រយឹង ព្រំប្រទល់ខេត្តកំពង់ស្ពឺ និងគ្របដណ្តប់ដល់ខេត្តកោះកុង ក្នុងនោះ ខ្សែបណ្តាញតង់ស្យុងមធ្យមមាន៖ ខ្សែបណ្តាញកប់ដីប្រវែង 148 km ខ្សែបណ្តាញអាកាស 1.438km និងខ្សែបណ្តាញក្រោមសមុទ្រ 3,90km។ ខ្សែបណ្តាញតង់ស្យុងទាបមាន៖ ខ្សែបណ្តាញកប់ដីប្រវែង 8,79km ខ្សែបណ្តាញអាកាស 269 km ត្រង់ស្វូលើបណ្តាញសរុប 2.045ត្រង់ស្វូ ដែលមានថាមពលអគ្គិសនីសរុប 1,036 MW និងកំពុងសាងសង់ខ្សែបណ្តាញអគ្គិសនីកប់ក្រោមបាតសមុទ្រ ឆ្លងកាត់តាមកោះ តាទាម កោះម្នាស់ និងកោះរ៉ុង ចាប់ពីឃុំកោះស្តេចស្រុកគីរីសាគរខេត្តកោះកុង មកដល់សង្កាត់កោះរ៉ុងក្រុងព្រះសីហនុ និងកោះស្រមោច ក្នុងឃុំរាមស្រុកព្រៃនប់ខេត្តព្រះសីហនុ ដោយយកប្រភពថាមពលអគ្គិសនីពីបណ្តាញជាតិ ទៅផ្គត់ផ្គង់ឱ្យសេវាករនៅលើកោះ ដើម្បីចែកចាយបន្តជូនបងប្អូនប្រជាពលរដ្ឋប្រើប្រាស់លើកោះ និងដើម្បីជួយជំរុញការអភិវឌ្ឍន៍លើកោះ។

### ៦.៤. ការងារទេសចរណ៍

- ចំនួនភ្ញៀវទេសចរមកកម្សាន្តក្នុងខេត្តព្រះសីហនុសរុប ១១.៥០៥.៤០៦នាក់ ក្នុងនោះភ្ញៀវជាតិ ៩.៣៨៥.២២៨នាក់ និងភ្ញៀវអន្តរជាតិ ២.១២០.១៧៨នាក់
- ចំនួនភ្ញៀវចូលតាមនាវា ១១៧.៣២៦នាក់ និងនាវិក ៥១.៤២៤នាក់
- ចំនួនភ្ញៀវតាមយន្តហោះ ១.០៩២.១៥៦នាក់ ក្នុងនោះភ្ញៀវជាតិ ៧.៤៨៣នាក់ និងភ្ញៀវអន្តរជាតិ ១.០៨៤.៦៧២នាក់
- ចំនួនភ្ញៀវកម្សាន្តតាមបណ្តាកោះសរុប ៧៧៥.៩៨៥នាក់ ក្នុងនោះ ភ្ញៀវជាតិ ២៨៤.៦៣៥នាក់ និងភ្ញៀវអន្តរជាតិ ៤៧១.០៣៥០នាក់
- ក្នុងឆ្នាំ២០២២ មូលដ្ឋានអាជីវកម្មទេសចរណ៍សរុបចំនួន ៣៩១កន្លែង កើនឡើង ១១៦កន្លែង ស្មើនឹង (៤២,១៨%) ធៀបនឹងឆ្នាំ២០២១ ក្នុងនោះមានអាជ្ញាប័ណ្ណ ៣៨២ទីតាំង (ចេញដោយក្រសួង ៧៣កន្លែង,ប្រកខេត្ត ២៧៨កន្លែង, ប្រកក្រុង ២៨កន្លែង, ប្រកស្រុកព្រៃនប់ ០៣កន្លែង)។
- មានបុគ្គលិកបំរើការងារផ្ទាល់ក្នុងវិស័យទេសចរណ៍សរុប ៧.៩៧២នាក់ ស្រី ៣.៧៥៥នាក់ កើនឡើង ២.៦៨៩នាក់ ស្មើនឹង (៥០,៨៩%)។

## ៧. ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

### ៧.១. ការងាររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី

#### ក. ការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

- បានប្រកាសតំបន់វិនិច្ឆ័យបានចំនួន ៤១ភូមិ ប្រមូលទិន្នន័យ(បំពេញForm) បានចំនួន ៣៦.០១២ក្បាលដី វាស់វែង និងគូសបានចំនួន ៤២.១៨៨ក្បាលដី បញ្ចូលទិន្នន័យបានចំនួន ២៦.២៣៦ក្បាលដី បិទផ្សាយបានចំនួន ២៣ភូមិ ស្មើនឹង ១៩៥៧៥ក្បាលដី និងចែកបណ្ណកម្មសិទ្ធិ បានចំនួន ៨.៤៨៤បណ្ណ។

#### ខ. ការងារអភិរក្សសុរិយោដី

បានចរន្តការ និងសម្រេចផ្តល់បណ្ណកម្មសិទ្ធិលើ ការងារចុះបញ្ជីដីធ្លីលើកដំបូងតាមលក្ខណៈដាច់ដោយដុំ, ការបង្កើតសិទ្ធិលើការបញ្ចាំ, ការបង្កើតហ៊ីប៉ូតែក, ការចុះបញ្ជីអំពីការលុបការបង្កើតសិទ្ធិលើការបញ្ចាំ, ការចុះបញ្ជីអំពីការលុបហ៊ីប៉ូតែក, ការផ្ទេរកម្មសិទ្ធិទាំងមូល, ការផ្ទេរកម្មសិទ្ធិដោយបំបែកក្បាលដី, ការបំបែកក្បាលដីដោយមិនផ្ទេរ, ការបង្រួមក្បាលដី, ការចេញបណ្ណទុតិយតា, ការប្តូរប្រភេទដី និងរូបភាពប្រើប្រាស់ដី, ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍, ការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ និងការលុបការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ, ការបញ្ជាក់ព័ត៌មានក្បាលដី, ការកែតម្រូវទំហំដី-រូបរាងដី សរុបចំនួន **៥៧.៧២៧** សំណុំឯកសារ។

**គ. ការងារបច្ចេកទេសសុរិយោដី និងភូមិសាស្ត្រ**

- បានចូលរួមសហការ និងវាស់វែងជាមួយស្ថាប័នពាក់ព័ន្ធដូចជា ក្រសួងជនស, ក្រុមការងារមន្ទីរដេនសស ខេត្ត, ស្ថាប័នតុលាការ, រដ្ឋបាលខេត្ត រដ្ឋបាលក្រុង/ស្រុក, មន្ទីរអង្គភាពពាក់ព័ន្ធ, ការិយាល័ ភូមិបាល ក្រុង/ស្រុក និងចូលរួមជាមួយក្រុមហ៊ុនឯកជន សរុបចំនួន ១៩៦៨ ករណី ។
- បានចុះវាស់វែងស្នើសុំកែតម្រូវរូបរាងដី, ស្នើសុំចេញលេខក្បាលដី, វាស់វែងស្នើសុំចេញបណ្ណកម្មសិទ្ធិ និងវាស់វែងស្នើសុំស្វែងរកចំណុចព្រំដីឡើងវិញ សរុបបានចំនួន ៨៩៧ករណី។

**ឃ. ការងារផ្តល់លិខិតអនុញ្ញាតសាងសង់**

សំណង់ស្នើសុំលិខិតអនុញ្ញាតសាងសង់ ពីឆ្នាំ**២០១៨** ដល់ឆ្នាំ**២០២២** មានចំនួន **១.៥៨៨ គម្រោង,** មានផ្ទៃក្រឡាសំណង់សរុប **១៤.៦៤៤.១៩០**ម$^{២}$, មានទុនវិនិយោគសរុប **៧.៩៨៩.២៦៣.៨៩០**ដុល្លារ រួមមាន៖

- សំណង់សមត្ថកិច្ចក្រសួងចំនួន ៤៥០គម្រោង ផ្ទៃក្រឡាសំណង់សរុប ១៣.៨៣១.១១១ម$^{២}$ ទុនវិនិយោគសរុប ៧.៦១៥.១៧៥.៤២៧ ដុល្លារ
- សំណង់សមត្ថកិច្ចខេត្តមានចំនួន ៣១៤គម្រោង ផ្ទៃក្រឡាសំណង់សរុប ៦០០.៤៣៤ម$^{២}$ មានទុនវិនិយោគសរុប ៣០៤.៧៩០.៥៨២ដុល្លារ
- សំណង់សមត្ថកិច្ចក្រុងចំនួន ៨២៤គម្រោង ផ្ទៃក្រឡាសំណង់សរុប ២១២.៦៤៥ម$^{២}$ មានទុនវិនិយោគសរុប ៦៩.២៩៧.៨៨១ដុល្លារ។

-**សំណង់អគារខ្ពស់ៗ** ពីឆ្នាំ២០១៨ ដល់ឆ្នាំ ២០២២ មានចំនួន ៥៨៩គម្រោង មានដូចខាងក្រោម៖

- ពី ៥ជាន់ - ៩ជាន់ មានចំនួន ២៦៣ គម្រោង
- ពី ១០ជាន់ - ១៩ជាន់ មានចំនួន ២២៩ គម្រោង
- ពី ២០ជាន់ - ២៩ជាន់ មានចំនួន ៦៣ គម្រោង
- ពី ៣០ជាន់ - ៣៩ជាន់ មានចំនួន ២៨ គម្រោង
- ចាប់ពី ៤០ជាន់ឡើងទៅ មានចំនួន ៦ គម្រោង

**ង. ការងាររៀបចំដែនដី និងនគរូបនីយកម្ម**

សមិទ្ធផលការងាររៀបចំដែនដី និងនគរូបនីយកម្ម គិតចាប់ពីពេលចាប់ផ្តើមរហូតដល់ដំណាច់ឆ្នាំ២០២២មាន៖ បានអនុម័តដាក់ឱ្យប្រើប្រាស់លើផែនការរៀបចំដែនដីខេត្តព្រះសីហនុ បានអនុម័តដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងព្រះសីហនុ និងបានអនុម័តដាក់ឱ្យប្រើប្រាស់លើប្លង់គោលប្រើប្រាស់ដីក្រុងកោះរ៉ុង និងកំពុងរៀបចំប្លង់គោលប្រើប្រាស់ដីស្រុកស្ទឹងហាវ។ បានសម្រេចដាក់ឱ្យប្រើប្រាស់លើផែនការប្រើប្រាស់ដីថ្នាក់ឃុំ/សង្កាត់ បានចំនួន ៨ ឃុំ/សង្កាត់ រួមមាន៖ ស្រុកព្រៃនប់ មាន ៥ ឃុំ ដូចជា ឃុំបឹងតាព្រហ្ម, ឃុំរាម, ឃុំអូរឧកញ៉ាហេង, ឃុំសំរុង, ឃុំអណ្តូងថ្ម, រីឯស្រុកស្ទឹងហាវ មាន ៣ ឃុំ ដូចជា ឃុំកំពេញ, ឃុំទំនប់រលក, ឃុំអូរត្រេះ។ បានសម្រេចដាក់ឱ្យប្រើប្រាស់ប្លង់បណ្តាញហេដ្ឋារចនាសម្ព័ន្ធផ្លូវសាធារណៈ

ចក្ខុវិស័យឆ្នាំ២០៣៨ បានចំនួន ២ឃុំ/សង្កាត់ គឺសង្កាត់លេខ១ នៃក្រុងព្រះសីហនុ និងមួយផ្នែកនៃឃុំបិតត្រាំង ស្រុកព្រៃនប់ និងកំពុងរៀបចំផែនការប្រើប្រាស់ដីសង្កាត់លេខ១ នៃក្រុងព្រះសីហនុ និងឃុំអូរជ្រៅនៃស្រុកព្រៃនប់ បន្តទៀត។

**ច. ការងារលំនៅឋាន និងសម្បទានដីសង្គមកិច្ច**

ផ្ទៃដីសម្បទានសង្គមកិច្ចនេះត្រូវបានកែសម្រួលទំហំដីមកត្រឹមទំហំ ១.០៤០ ហិកតា តាមរយៈអនុក្រឹត្យលេខ ៥២ អនក្រ បក.ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ ។

ដីសម្បទានសង្គមកិច្ច ត្រូវបានបែងចែកអស់ផ្ទៃដីទំហំប្រមាណ ៥៣៧ ហិកតា ០៧អា ២៨សង្ទីអា ដែលចែកចេញជា ២ផ្នែក៖ ផ្នែកទី១ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីខេត្តព្រះសីហនុ ដីសម្បទានសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ មានផ្ទៃដីសរុបទំហំ ៣៨២ ហិកតា ៣០អា ៣៩សង្ទីអា ក្នុងនោះ៖ បានបែងចែកជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ចំនួន ១៨២គ្រួសារ ស្មើនឹងដីទំហំ ៣០២ ហិកតា (ដីឡូត៏លំនៅឋានមានទំហំ ៧៥ ហិកតា ដែលក្នុង ១គ្រួសារ ទទួលបានដីទំហំ ៣០ម x៤០ម, និងដីឡូត៏កសិកម្មមានទំហំ ២២៧ហិកតា ដែលក្នុង ១គ្រួសារ ទទួលបានដីទំហំ ១ហិកតា។) ចំពោះផ្ទៃដីនៅសល់ទំហំប្រមាណ ៣៣ ហិកតា ៦៧អា ០៧សង្ទីអា ទៀត គឺជាដីគ្រោងបម្រុងទុក ដូចជាតំបន់រដ្ឋបាល មណ្ឌលសុខភាព សាលារៀននិងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ រួមមានប្រព័ន្ធអូរ និងផ្លូវសាធារណៈ។ ផ្នែកទី២៖ ការបែងចែកដីសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រ ទំហំប្រមាណ ១៥៥ ហិកតា ០៧អា ២៨សង្ទីអា ស្មើនឹង ២៣៧គ្រួសារ ក្នុងនោះការបែងចែកដីមាន ២ លើក៖ លើកទី១៖ បានចែកដីជូនប្រជាពលរដ្ឋក្រីក្រ ចំនួន ១៨៨ គ្រួសារ ស្មើនឹងដីទំហំ ១៣២ ហិកតា ៥០អា ២៨សង្ទីអា ក្នុងមួយគ្រួសារទទួលបានដីទំហំ ៥០ម x១០០ម។ លើកទី២៖ បានចែកដីជូនប្រជាពលរដ្ឋចំនួន ៤៩គ្រួសារ ស្មើនឹងដីទំហំ ២២ ហិកតា ៥៧អា ក្នុងមួយគ្រួសារទទួលបានដីទំហំ ៥០ម x៥០ម ។

**ឆ.ការងារដោះស្រាយវិវាទដីធ្លី សំណើសុំផ្សេងៗពាក់ព័ន្ធដីធ្លី និងការងារតុលាការ**

ការងារដោះស្រាយវិវាទដីធ្លី និងសំណើសុំពាក់ព័ន្ធនឹងដីធ្លី សម្រេចបាន៖ ១.អំពីវិវាទដីធ្លីដែលទទួលបានពីក្រសួង រដ្ឋបាលខេត្ត និងប្រជាពលរដ្ឋ មានសរុបចំនួន ៣២៣ករណី ជាលទ្ធផលបានដោះស្រាយ, បានធ្វើរបាយការណ៍, ឆ្លើយតបបានចំនួន ២៨៥ករណី និងនៅសល់ ៣៨ករណីទៀត មន្ទីរកំពុងខិតខំដោះស្រាយ។ ២.អំពីសំណើសុំពាក់ព័ន្ធនឹងដីធ្លី ទទួលបានសរុបចំនួន ២៩១ករណី ជាលទ្ធផលបានដោះស្រាយ បានធ្វើរបាយការណ៍, ឆ្លើយតបបានចំនួន ២៣៧ករណី និងនៅសល់ ៥៤ករណីទៀត មន្ទីរកំពុងខិតខំដោះស្រាយ។ ៣.អំពីការដោះស្រាយវិវាទដីធ្លីក្នុងយន្តការគណៈកម្មការសុរិយោដី គឺទទួលបានសរុបចំនួន ១៦៤ករណី ជាលទ្ធផលបានដោះស្រាយបញ្ចប់, បានសម្រុះសម្រួលឱ្យម្ចាស់បណ្តឹង ដកពាក្យបណ្តឹងវិញ, បានច្រានចោល និងបញ្ជូនឡើង បានទាំងស្រុង គឺពុំមានសេសសល់ទេ ដោយឡែកសម្រាប់ឆ្នាំ២០២៣នេះ គណៈកម្មការសុរិយោដីខេត្តបានលើកផែនការស្នើសុំដោះស្រាយវិវាទដីធ្លីចំនួន ២០ករណីទៀត តាមយន្តការក្រុមការងារដោះស្រាយវិវាទដីធ្លីចល័ត។

នៅថ្ងៃទី៣១ ខែ មករា ឆ្នាំ ២០២៣ រដ្ឋបាលខេត្តព្រះសីហនុបានជួបប្រជុំពិភាក្សា ពិគ្រោះយោបល់ អន្តរក្រសួង-ស្ថាប័ន ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីពិភាក្សាលើការរៀបចំវិធានការលើកទឹកចិត្ត និងវិធានការដាក់ពិន័យសម្រាប់ដោះស្រាយគម្រោងវិនិយោគ និងអគារជាប់គាំងក្នុងខេត្តព្រះសីហនុ។ អង្គប្រជុំ បានពិភាក្សាលើនិយមន័យគម្រោងវិនិយោគជាប់គាំង វិធានការទូទៅ វិធានការលើកទឹកចិត្ត និងផែនការសកម្មភាព ដែលក្រុមការងារបានធ្វើការសិក្សាស្រាវជ្រាវ។ ជាលទ្ធផលអង្គប្រជុំ បានឯកភាពលើការ

ស្នើឡើងនូវនិយមន័យ និងវិធានការទាំងនេះ និងបានកែសម្រួលបន្ថែម ដើម្បីគោរពរាយការណ៍ សុំការសម្រេចរបស់ថ្នាក់ដឹកនាំ។

### ៧.២. វិស័យបរិស្ថាន

**ក. ការងារទីលានទុកដាក់សំរាម សំណល់រឹង**

- ទីលានទុកដាក់សំរាមសំណល់រឹងនៅខេត្តព្រះសីហនុ ជាប្រភេទទីលានអនាម័យដំបូងបង្អស់របស់ប្រទេសកម្ពុជា ដែលត្រូវបានសិក្សាបច្ចេកទេស និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដោយអនុគម្រោងអភិវឌ្ឍន៍ទីក្រុងរបៀងជំហាន២ក្រោមឥណទាន ធនាគារ ADB នៅឆ្នាំ២០១៩
- ក្រោមការឯកភាពដ៏ខ្ពង់ខ្ពស់ពីសម្តេចតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីលានទុកដាក់សំរាមត្រូវបានសាងសង់ឡើងដោយប្រើប្រាស់ថវិកាជាតិស្របតាមគោលនយោបាយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធខេត្តព្រះសីហនុ
- ទីលានទុកដាក់សំរាមចាប់ផ្តើមសាងសង់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ឆ្នាំ២០២១ គម្រោងសាងសង់អនុវត្តដោយក្រសួងសាធារណៈការ និងដឹកជញ្ជូន
- ដំណាក់កាលទីមួយនេះទីលានសាងសង់លើផ្ទៃដីទំហំ១៧ហត នៃផ្ទៃដីសរុប៦៥,៤៥ហត សាងសង់៤រណ្តៅ ដែលរណ្តៅនីមួយៗមានទំហំប្រហែល ២ហត និងមានជម្រៅ ៣,៥ម ទីលានចាប់ផ្តើមដំណើរការនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ និងត្រូវបានព្យាករណ៍ថានឹងអាចប្រើប្រាស់បានរយៈពេល ៥ឆ្នាំ (ដល់ឆ្នាំ២០២៥)
- ទីលានទទួលទុកដាក់សំរាមពីក្រុងព្រះសីហនុ និងស្រុកព្រៃនប់ ដែលសំរាមចូលទីលានជាមធ្យមប្រហែល ៤៥០តោនក្នុងមួយថ្ងៃ។
- ក្រសួងបរិស្ថាន បានផ្តល់រថយន្តដឹកសំរាម ម៉ូតូកង់បីដឹកសំរាម និងឡដុតសំរាម ជូនទៅក្រុងកោះរ៉ុង រថយន្តដឹកសំរាម០២គ្រឿង ឡដុតសំរាម០២គ្រឿង ស្រុកស្ទឹងហាវ រថយន្តដឹកសំរាម០១គ្រឿង ម៉ូតូកង់បីដឹកសំរាម០១គ្រឿង ឡដុតសំរាម០២គ្រឿង ស្រុកកំពង់សីលា រថយន្តដឹកសំរាម០១គ្រឿង ម៉ូតូកង់បីដឹកសំរាម០២គ្រឿង និងស្រុកព្រៃនប់ រថយន្តដឹកសំរាម០១គ្រឿង ឡដុតសំរាម០១គ្រឿង ឡដុតសំរាមនីមួយៗ មានសមត្ថភាពដុតសំរាមបានប្រមាណពី ២តោន/ថ្ងៃ ទៅដល់ ៤តោន/ថ្ងៃ។

**ខ. ការគ្រប់គ្រងសំណល់រាវ**

- រដ្ឋបាលខេត្តព្រះសីហនុ បានសហការជាមួយនឹងគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា សម្រេចសាងសង់ស្ថានីយប្រព្រឹត្តិកម្មទី១ ទី២ និងទី៣ ក្នុងគោលបំណងធ្វើប្រព្រឹត្តិកម្មសម្អាតទឹកកខ្វក់ ឱ្យក្លាយជាទឹកដែលស្អាតស្របតាមស្តង់ដារបរិស្ថានមុននឹងបញ្ចេញចោលទៅសមុទ្រដោយប្រើបច្ចេក វិទ្យាចុងក្រោយ MABR ដែលត្រូវបានគេទទួលស្គាល់ថាជាបច្ចេកវិទ្យាដែលមានស្ថេរភាព ប្រសិទ្ធភាពខ្ពស់ សន្សំសំចៃថាមពលគ្មានសំឡេងរំខាន និងគ្មានក្លិនប៉ះពាល់ដល់អ្នករស់នៅជុំវិញក្នុងនោះ៖ ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ទី១ មានសមត្ថភាពប្រព្រឹត្តិកម្មទឹកកខ្វក់ក្នុងបរិមាណ ៥.២០០ម៉ែត្រគូបក្នុងមួយថ្ងៃ ទទួលរងទឹកកខ្វក់ពីតំបន់ទី៣ ដែលមានផ្ទៃដី ៣៦៤ហិកតា និងមានប្រជាជន ១៤.៤៩២នាក់ (គិតក្នុងឆ្នាំ២០៣០)។ ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ទី២ មានសមត្ថភាពប្រព្រឹត្តិកម្មទឹកកខ្វក់ក្នុងបរិមាណ ៧.២០០ម៉ែត្រគូប ក្នុងមួយថ្ងៃ ទទួលរងទឹកកខ្វក់ពីតំបន់ទី៤ ដែលមានផ្ទៃដី ៤៨៦ហិកតា និងមានប្រជាជន ២៣.៣៩១នាក់ (គិតក្នុងឆ្នាំ២០៣០)។ ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ទី៣ មានសមត្ថភាពប្រព្រឹត្តិកម្មទឹកកខ្វក់ក្នុងបរិមាណ ២០.០០០ម៉ែត្រគូប ក្នុង

មួយថ្ងៃ ទទួលរងទឹកកខ្វក់ពីតំបន់ទី៥ និងតំបន់ទី៦ ដែលមានផ្ទៃដី ២.៦៩០ហិកតា និងមានប្រជាជន ១៣៣.៨១១នាក់ (គិតក្នុងឆ្នាំ២០៣០)។ ព្រមទាំងសាងសង់ស្ថានីយ៍បូម ដោយគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា ០៣ទីតាំង និងមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ចំនួន ០៤ទីតាំង។

## III. **ទិសដៅការងារបន្ត**

- បន្តអនុវត្តគោលនយោបាយភូមិ-ឃុំ/សង្កាត់ មានសុវត្ថិភាព
- បន្តលើកម្ពស់គោលការណ៍អភិបាលកិច្ចល្អ ការកែទម្រង់ប្រព័ន្ធរដ្ឋបាល ដោយពង្រីកវិសាលភាពសេវាកម្មផ្តល់ដោយរដ្ឋបាលខេត្ត ឱ្យបានទូលំទូលាយ
- បន្តបង្វិតរដ្ឋបាលឱ្យនៅកៀកជិតនឹងប្រជាពលរដ្ឋ បង្កភាពងាយស្រួលក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យបានឆាប់រហ័ស ប្រកបដោយប្រសិទ្ធភាព គុណភាព តម្លាភាព
- បន្តខិតខំរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយ នៅតាមបណ្តាផ្លូវ បណ្តោយឆ្នេរ និងទីសាធារណៈក្នុង ភូមិសាស្ត្រខេត្តព្រះសីហនុ ដើម្បីរក្សាបាននូវបរិស្ថានស្អាត និងសោភ័ណភាពទីក្រុងស្អាត
- បន្តផ្សព្វផ្សាយពីវិធានការ ការពារ ទប់ស្កាត់ គ្រប់គ្រង និងប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ ឱ្យបានទាន់ពេលវេលា និងបន្តយុទ្ធនាការកិច្ចការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ ឱ្យបានគ្រប់ផែនការ
- បន្តអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

ជាទីបញ្ចប់ខ្ញុំបាទ សូមគោរពជូនពរ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក-លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ សូមទទួលបានសុខភាពល្អ អាយុវែង សុភមង្គលក្នុងក្រុមគ្រួសារ និងទទួលបានជោគជ័យគ្រប់ភារកិច្ចការងារ ព្រមទាំងជួបប្រទះនូវពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!!!